# BACCALAURÉAT TECHNOLOGIQUE

**SESSION 2016**

**CAMBODGIEN**

**VENDREDI 17 JUIN 2016**

LANGUE VIVANTE **1**

Séries : **Hôtellerie, STI2D, STD2A, STL, ST2S** – Durée de l'épreuve : **2 heures** – coefficient **2**

Série **STMG** – Durée de l'épreuve : **2 heures** – coefficient **3**

**Le candidat traitera, dans la langue étrangère, l'ensemble des questions de l'épreuve pour laquelle il compose.**

*L'usage des dictionnaires et des calculatrices électroniques est interdit.*

Dès que ce sujet vous est remis, assurez-vous qu'il est complet.
Ce sujet comporte 4 pages numérotées de 1/4 à 4/4.

**Répartition des points**

| | |
|---|---|
| Compréhension de l'écrit | 10 points |
| Expression écrite | 10 points |

អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន ដែលជាអង្គការអន្តរជាតិមួយការពារអ្នកសារព័ត៌មានទូទាំងពិភពលោក ដែលមានមូលដ្ឋាននៅប្រទេសបារាំង បានចងក្រងឯកសារមួយដែលប្រមូលផ្តុំដោយប្រវត្តិអ្នកកាសែតចំនួន ១០០ នាក់ មកផ្សព្វផ្សាយ ដើម្បីបង្ហាញសាធារណជន នាទិវាសេរីភាពសារព័ត៌មានពិភពលោក ថ្ងៃទី ៣ ឧសភា ។

ការណ៍នេះគឺជាលើកទីមួយហើយ ដែលអង្គការនេះបានជ្រើសរើសយ៉ាងសម្រិតសម្រាំងអ្នកកាសែតចំនួន ១០០ នាក់ ដែលមានអាយុចាប់ពី ២៥ ឆ្នាំដល់ ៧៥ ឆ្នាំ ពីប្រទេសចំនួន ៦៥ ក្នុងនោះ គឺមានប្រទេសកម្ពុជាផងដែរ ។

ពីរដ្ឋធានីវ៉ាស៊ីនតោន អ្នកនាង កេសរណ្ណីយ្យា ជូនសេចក្តីរាយការណ៍អំពីរឿងនេះ ៖

*អ្វីដែលញ៉ាំងឲ្យបុរសស្ត្រីទាំង ១០០ នាក់នោះ បានទទួលកិត្តិយសផ្តល់ងារជាវីរជន គឺភាពអង់អាចក្លាហាន និងសកម្មភាពក្នុងការបំពេញតួនាទីជួយលើកកម្ពស់សិទ្ធិមនុស្ស រួមមានសេរីភាពក្នុងការទទួលនិងចែកចាយព័ត៌មាន ព្រមទាំងសេរីភាពក្នុងការបញ្ចេញមតិ តាមរយៈបណ្តាញផ្សព្វផ្សាយដោយគ្មានកម្រិតព្រំដែន ។*

*ក្នុងចំណោមអ្នកសារព័ត៌មានទាំង ១០០ នាក់ ដែលអង្គការអន្តរជាតិមួយនេះ បានចាត់ទុកជាវីរជនព័ត៌មាន លោក តាត ឧត្តម គឺជាអ្នកកាសែតខ្មែរ ដែលមានវ័យក្មេងជាងគេបង្អស់ ។*

*អ្នកគ្រប់គ្រងកម្មវិធីវិទ្យុ « សំឡេងប្រជាធិបតេយ្យ » នៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ លោក ដួង សុខា ឲ្យដឹងថា ការដែលលោក តាត ឧត្តម ត្រូវបានជ្រើសរើសជាវីរជនព័ត៌មាននេះ គឺជាកិត្តិយសសម្រាប់មជ្ឈមណ្ឌលផង សម្រាប់អ្នកកាសែតខ្មែរ និងសម្រាប់ប្រទេសជាតិផងដែរ ៖* « លោក តាត ឧត្តម គឺគាត់ស្វះស្វែងណាស់ នៅពេលដែលមានព្រឹត្តិការណ៍អ្វីកើតឡើងម្តង ៗ ដូចជា ការប៉ះទង្គិចគ្នារវាងបាតុករ ហើយនិងខាងកម្លាំងសមត្ថកិច្ចអី គឺដូចជាថ្ងៃនេះ គឺជាទិវាពលកម្មអន្តរជាតិអ៊ីចឹង គាត់បានចុះទៅទីតាំងផ្ទាល់ ហើយបានផ្តិតយករូបភាព ដែលខាងកម្លាំងសន្តិសុខធ្វើការវាយទៅលើក្រុមប្រជាពលរដ្ឋអ៊ីចឹងហើយ បាទ... ទោះបីជាមានបញ្ហាប្រឈមអីក៏ដោយ ក៏គាត់នៅតែព្យាយាមបង្ហាញថា អ្វីដែលកំពុងកើតមានក្នុងសង្គម ជូនទៅដល់ប្រជាពលរដ្ឋអ៊ីចឹងហើយ បាទ... » ។

*លោក តាត ឧត្តម ដែលបានចាប់ចិត្តនឹងការងារក្នុងវិស័យសារព័ត៌មាននេះតាំងពីអាយុ ១៣ ឆ្នាំ កាលនៅជាក្មេងលក់កាសែតម្នាក់នៅឡើយនោះ បានឲ្យដឹងពីស្នាដៃចម្បងមួយ ដែលជាកត្តាញ៉ាំងឲ្យលោកត្រូវបានជ្រើសរើសជាវីរជនព័ត៌មាននេះ ៖* « ស្នាដៃផ្ទាល់ខ្លួនរបស់ខ្ញុំ គឺខ្ញុំបានផលិតជាវីដេអូស៊ើបអង្កេតទាក់ទងជាមួយនឹងករណីបាញ់ទៅលើកម្មការិនី ៣ នាក់នៅខេត្តស្វាយរៀង ហើយជាវីដេអូដែលមានប្រហែលជា ១៣ ទៅ ១៥ នាទីនេះ ក៏ខ្ញុំបានដាក់ប្រកួតពានរង្វាន់ដែលមានឈ្មោះថា ឌីជាប់បែលយូ អាក់ឌីដែមីកា ហើយពេលនោះ ក៏ខ្ញុំត្រូវបានជាប់ជាជម្រើសរបស់គេដែរ ។ ហើយអ្វីផ្សេងទៀតដែលគេជ្រើសរើស គឺខ្ញុំបានប្រឈមមុខនឹងបញ្ហាជាច្រើន ពីសំណាក់រដ្ឋាភិបាល និងជនមិនស្គាល់ដែលបានវាយប្រហារមកលើរូបខ្ញុំ » ។

*ចាប់ពីឆ្នាំ ២០១១ មក លោក តាត ឧត្តម បានបម្រើការជាអ្នកយកព័ត៌មាននៃកម្មវិធីវិទ្យុសំឡេងប្រជាធិបតេយ្យ ដែលជាវិទ្យុមួយក្នុងចំណោមស្ថានីយវិទ្យុឯករាជមួយចំនួនតូចនៅក្នុងប្រទេសកម្ពុជា ដែលហ៊ានរាយការណ៍ព័ត៌មានពីចំណុចខ្វះខាតរបស់រាជរដ្ឋាភិបាល និងបញ្ហាសំខាន់ ៗ ក្នុងសង្គមខ្មែរ ក្នុងគោលបំណងឲ្យមានការផ្លាស់ប្តូរនិងការអភិវឌ្ឍផ្នែកលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សក្នុងសង្គមជាតិកម្ពុជា ៕*

« អ្នកកាសែតខ្មែរវ័យក្មេង ទទួលងារជាវីរជនព័ត៌មាន » ដោយ កេសរណ្ណីយ្យា
វិទ្យុអាស៊ីសេរី ០២/០៥/២០១៤

http://www.rfa.org/khmer/news/human-rights/The-Youngest-Cambodian-Journalist-Hero-05022014064954.html ។

## Vocabulaire ~ វាក្យសព្ទ

๏ កត្តា ៖ facteur
๏ កម្មការិនី ៖ ouvrière
๏ កម្មវិធី ៖ programme
๏ ករណី ៖ cas
๏ ការពារ ៖ défendre, protéger
๏ កិត្តិយស ៖ honneur
๏ ងារ ៖ titre
๏ ឌីដាប់បែលយូ អាកាដេមីកា ៖ DW Academica
๏ ទិវា ៖ journée
๏ បណ្ដាញផ្សព្វផ្សាយ ៖ réseau de diffusion
๏ បាតុករ ៖ manifestant
๏ ប្រជាធិបតេយ្យ ៖ démocratie; démocratique
๏ ប្រជាពលរដ្ឋ ៖ citoyen
๏ ប្រព័ន្ធផ្សព្វផ្សាយ ៖ mass média
๏ ប្រវត្តិ ៖ histoire; biographie; profil
๏ ផលិត ៖ produire
๏ ព័ត៌មាន ៖ information
๏ ពលកម្ម ៖ travail
๏ ពិភពលោក ៖ monde
๏ ព្រឹត្តិការណ៍ ៖ événement
๏ មជ្ឈមណ្ឌល ៖ centre
๏ មតិ ៖ opinion
๏ មានមូលដ្ឋាន ៖ être basé
๏ មូលដ្ឋាន ៖ base
๏ រដ្ឋធានី ៖ capitale (d'une république)
๏ រាជរដ្ឋាភិបាល ៖ gouvernement royal
๏ លទ្ធិ ៖ doctrine
๏ វ័យ ៖ អាយុ
๏ វិទ្យុ ៖ រ៉ាឌីយោ
๏ វិស័យ ៖ domaine
๏ វីរជន ៖ héros
๏ សកម្មភាព ៖ activité
๏ សង្គម ៖ société ; social
๏ សន្តិសុខ ៖ sécurité
๏ សម្រិតសម្រាំង ៖ faire avec beaucoup de soin
๏ សាធារណជន ៖ public
๏ សិទ្ធិ ៖ droit
๏ សេរីភាព ៖ liberté
๏ ស្ថានីយ ៖ station
๏ អង្គការ ៖ organisation
๏ អង្គការអ្នកសាព័ត៌មានគ្មានព្រំដែន ៖ organisation « Reporters sans frontières »
๏ អន្តរជាតិ ៖ international
๏ អភិវឌ្ឍ ៖ développer ; se développer
๏ អ្នកសារព័ត៌មាន = អ្នកកាសែត ៖ journaliste
๏ ឯករាជ ៖ indépendant(e) (adj.)
๏ ឯករាជ្យ ៖ indépendance
๏ ឯកសារ ៖ document

# TRAVAIL À FAIRE PAR LE CANDIDAT

## I. COMPRÉHENSION DE L'ÉCRIT (10 points)

**ក.** តើអង្គការការពារអ្នកសារព័ត៌មានទូទាំងពិភពលោក មានឈ្មោះអ្វី និងមានមូលដ្ឋាននៅប្រទេសណា ? (២ ពិន្ទុ)

**ខ.** តើអង្គការនេះបានជ្រើសរើសអ្នកកាសែតប៉ុន្មាននាក់ ដែលមកពីប្រទេសចំនួនប៉ុន្មាន ? (២ ពិន្ទុ)

**គ.** តើអ្នកកាសែតទាំងនោះបានទទួលងារអ្វី និងដោយមូលហេតុអ្វីខ្លះ ? (៣ ពិន្ទុ)

**ឃ.** មុននឹងក្លាយជាអ្នកកាសែត និងជាអ្នកយកព័ត៌មាន តើលោក តាត ឧត្តម ធ្លាប់ធ្វើការងារអ្វី ? (១ ពិន្ទុ)

**ង.** ហេតុអ្វីបានជាលោក តាត ឧត្តម បានទទួលពានរង្វាន់ ឌីដាប់បែលយូ អាកាដេមិកា ? (២ ពិន្ទុ)

## II. EXPRESSION ÉCRITE (10 points)

**Afin de respecter l'anonymat de votre copie, vous ne devez pas signer votre composition, citer votre nom, celui d'un camarade ou celui de votre établissement.**

**Les candidats traitent la question en 180 mots minimum.**

តើគេអាចទុកចិត្តព័ត៌មាន ដែលអ្នកកាសែតរាយការណ៍ បានទាំងស្រុងឬទេ ? ដើម្បីដឹងថា ព័ត៌មានដែលអ្នកអានក្នុងកាសែត មើលតាមកញ្ចក់ទូរទស្សន៍ និងអ៊ិនធើរណេត ឬស្តាប់តាមវិទ្យុ មានភាពត្រឹមត្រូវឬទេ តើអ្នកអាចផ្ទៀងផ្ទាត់បានយ៉ាងដូចម្តេច ? ចូរបញ្ចេញយោបល់ឲ្យបានក្បោះក្បាយ ៕